# ការបញ្ចុះតម្លៃថាមពល

## ត្រូវប្រាកដថាអ្នកកំពុងទទួលបានការបន្ថយតម្លៃថាមពលរបស់អ្នក ប្រសិនបើអ្នកមានប័ណ្ណសម្បទាន

ប្រសិនបើអ្នកមាន**ប័ណ្ណថែទាំសុខភាព (Health Care Card), ប័ណ្ណសម្បទានប្រាក់សោធននិវត្តន៍ (Pension Concession Card) ឬប័ណ្ណអតីតយុទ្ធជនពណ៌មាស (Veteran Affairs Gold Card)** អ្នកមានសិទ្ធិទទួលបានអគ្គិសនី និងឧស្ម័នដែលមានតម្លៃថោកជាង។ ប្រសិនបើអ្នកមិនមានប័ណ្ណសម្បទានណាមួយក្នុងចំណោមប័ណ្ណសម្បទានទាំងបីនេះទេ អ្នកមិនអាចសុំការបញ្ចុះតម្លៃថាមពលបានទេ។

ការបន្ថយតម្លៃថាមពលអាចជួយសន្សំប្រាក់អ្នករាប់រយដុល្លារជារៀងរាល់ឆ្នាំ។ ប្រសិនបើអ្នកមានប័ណ្ណសម្បទាន សូមទូរសព្ទទៅក្រុមហ៊ុនថាមពលលក់រាយរបស់អ្នក ហើយស្នើសុំឱ្យពួកគេពិនិត្យមើលថាអ្នកកំពុងទទួលបានការបន្ថយតម្លៃថាមពលរបស់អ្នកឬអត់។

ប្រសិនបើអ្នកផ្លាស់ប្ដូរទីលំនៅ ផ្លាស់ប្ដូរក្រុមហ៊ុនថាមពល ឬទទួលបានប័ណ្ណសម្បទានថ្មី ការបន្ថយតម្លៃរបស់អ្នកនឹងមិនអនុវត្តចំពោះវិក្កយបត្ររបស់អ្នកទេ។ ត្រូវប្រាកដថាអ្នកពិនិត្យមើលវិក្កយបត្ររបស់អ្នកជាទៀងទាត់ ដើម្បីធានាថាអ្នកកំពុងទទួលបានការបន្ថយតម្លៃថាមពលរបស់អ្នក។

### ឧទាហរណ៍នានានៃប័ណ្ណសម្បទាន៖



Health Care Card



Pension Concession Card



Veterans Affairs Gold Card

## របៀបស្នើសុំក្រុមហ៊ុនថាមពលលក់រាយរបស់អ្នក ឱ្យពិនិត្យមើលថាអ្នកកំពុងទទួលបានការចុះតម្លៃថាមពលរបស់អ្នក

### មុនពេលអ្នកហៅទូរសព្ទ៖

ត្រូវប្រាកដថាអ្នកមាន៖

- វិក្កយបត្រថ្មីមួយនៃអគ្គិសនី ឬឧស្ម័ន
- ព័ត៌មានលម្អិតអំពីគណនីថាមពលរបស់អ្នក (ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត លេខគណនី)
- ប័ណ្ណសម្បទានរបស់អ្នក។

**តើត្រូវការអ្នកបកប្រែផ្ទាល់មាត់ទេ?**
វិក្កយបត្រថាមពលរបស់អ្នក
នឹងមានដាក់បញ្ចូលព័ត៌មានសម្រាប់សេវាកម្មបកប្រែ
ផ្ទាល់មាត់ឥតគិតថ្លៃ។

### នៅពេលអ្នកហៅទូរសព្ទ៖

សូមប្រាប់ក្រុមហ៊ុនថាមពលលក់រាយរបស់អ្នក៖

**"ខ្ញុំមានប័ណ្ណសម្បទាន។ សូមអ្នកជួយពិនិត្យមើល ដើម្បីប្រាកដថា ខ្ញុំទទួលបានការចុះតម្លៃថាមពលទាំងអស់របស់ខ្ញុំ"**

## ប្រាក់ជំនួយសង្គ្រោះសម្រាប់សេវាកម្មចាំបាច់ (Utility Relief Grant)៖

ប្រសិនបើអ្នកមិនអាចបង់វិក្កយបត្រថាមពលរបស់អ្នកបានទេ អ្នកប្រហែលជាអាចទទួលប្រាក់ជំនួយសង្គ្រោះសម្រាប់សេវាកម្មចាំបាច់ (Utility Relief Grant)។ នេះគឺជាប្រាក់ជំនួយ $650 ដើម្បីជួយបង់វិក្កយបត្រនានាដែលនៅជំពាក់។ ប្រាក់ជំនួយនេះមានសម្រាប់អ្នកកាន់ប័ណ្ណសម្បទានដែលកំពុងជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុ។ សូមហៅទូរសព្ទទៅក្រុមហ៊ុនថាមពលលក់រាយរបស់អ្នក ហើយសួរអំពីប្រាក់ជំនួយសង្គ្រោះសម្រាប់សេវាកម្មចាំបាច់។



VICTORIA State Government | Environment, Land, Water and Planning